# បទវិចារណកថា៖ ចិននៅក្នុងបរិបទសម្ព័ន្ធភាពត្រីភាគី AUKUS

សម្ព័ន្ធភាពត្រីភាគី AUKUS ដឹកនាំដោយ សហរដ្ឋអាម៉េរិក អង់គ្លេស និងអូស្ត្រាលី។ សម្ព័ន្ធភាព AUKUS បានលេចចេញជារូបរាងឡើង កាលពីថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០២១ នឹងបានប្រកាសពីភាពជាដៃគូសន្តិសុខ នៅក្នុងតំបន់អាស៊ីប៉ាស៊ីហ្វិក។ សម្ព័ន្ធភាពត្រីភាគីបានអង្រួនឱ្យអន្តរជាតិចាប់អារម្មណ៍នោះ គឺដោយសារ សហរដ្ឋអាម៉េរិក និងអង់គ្លេសបានយល់ព្រម ផ្ទេរបច្ចេកវិទ្យាផលិតនាវាមុជទឹកដើរដោយថាមពលនុយក្លេអ៊ែរដល់អូស្ត្រាលីដែលនាវានេះអាចប្រើបានដល់២៥ឆ្នាំ ដោយពុំចាំបាច់ចាក់សាំង ឬម៉ាស៊ូត ហើយជាទូទៅវាអាចស្ថិតនៅក្រោមទឹកបាន៣ខែ។ បក្សសម្ព័ន្ធចាស់ដែលស្រដៀងគ្នានេះដែរ គឺកិច្ចសន្ទនាសន្តិសុខចតុភាគី ហៅថាQuad (មានមេដឹកនាំមកពីអូស្ត្រាលី ឥណ្ឌា ជប៉ុន និងអាមេរិក និងបានបង្កើតឡើងនៅឆ្នាំ២០០៧ នៅក្រៅក្របខណ្ឌនៃកិច្ចប្រជុំកំពូលអាស៊ានក្នុងប្រទេសហ្វីលីពីន) បានមានសកម្មភាពឡើងវិញ នឹងមានជំនួបគ្នាដោយផ្ទាល់លើកដំបូង នាថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០២១ នៅសេតវិមាន ដើម្បីធ្វើការពិភាក្សាលើបញ្ហាជាច្រើន រួមទាំងសន្តិសុខដែនសមុទ្រ កិច្ចសហប្រតិបត្តិការ វ៉ាក់សាំងប្រឆាំងកូវីដ ក៏ដូចជាស្ថានភាពនៅប្រទេសអាហ្វហ្គានីស្ថាន នៅក្នុងកិច្ចប្រជុំកំពូលលើកដំបូងនៃ «កិច្ចសន្ទនាសន្តិសុខ៤ប្រទេស»។ តាមសេចក្តីថ្លែងការណ៍រួមមួយ របស់សម្ព័ន្ធភាពត្រីភាគី AUKUS ថា *ភាពជាដៃគូថ្មីនេះ មានគោលបំណងក្នុងការ «លើកកម្ពស់សន្តិសុខ និង វិបុលភាព» ក្នុងតំបន់*។ ក្រោយមករដ្ឋាភិបាលទីក្រុងប៉ារីស បានហៅកិច្ចព្រមព្រៀងនេះថា *"ជាកិច្ចព្រមព្រៀងនាំទុក្ខ"* ។

សូមរំលឹកប្រវត្តិសាស្ត្រដែលបានកើតឡើងចំនួន៣សំខាន់ៗ **ទី១.**នៅថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ១៩៤០ អាល្លឺម៉ង់ ជប៉ុននិងអ៊ីតាលី បានចុះហត្ថលេខាលើកតិកាសញ្ញាត្រីភាគី នៅក្នុងទីក្រុងបែរឡាំង គឺបន្ទាប់ពីមួយឆ្នាំនៃការចាប់ផ្តើមសង្គ្រាមលោកលើកទីពីរ។ គោលបំណងបង្កើតសម្ព័ន្ធត្រីភាគីនេះគឺ ដើម្បីការពារប្រទេសសម្ព័ន្ធមិត្ត ហើយនោះគោលបំណងធំ ដើម្បីរាំងសហរដ្ឋអាម៉េរិក មិនឱ្យចូលក្នុងជម្លោះនេះ ពិសេសជាមួយជប៉ុននៅតំបន់អាស៊ីប៉ាស៊ីហ្វិក។ ក្រោយមកទៀតក៏មានប្រទេសជាច្រើនបានចូលក្នុងភាគីនៃកតិកាសញ្ញានេះ ក្នុងនោះមានហុងគ្រី រ៉ូម៉ានី ស្លូវ៉ាគី ប៊ុលហ្គារី យូហ្គោស្លាវី និងក្រូអាស៊ី។ **ទី២.**កាលពីឆ្នាំ១៩៦២ វិបត្តិមីស៊ីលគុយបា បានរុញឱ្យពិភពលោកទាំងមូលស្ថិតនៅមាត់ជ្រោះនៃសង្គ្រាមនុយក្លេអ៊ែរម្តងរួចមកហើយ ជាពេលដែលអាម៉េរិក និងសូវៀតគំរាមប្រើប្រាស់អាវុធនុយក្លេអ៊ែរដាក់គ្នាទៅវិញទៅមក ខណៈការរត់ប្រណាំងអាវុធមានទម្រង់ដូចគ្នាទៅនឹងអាម៉េរិក និងសូវៀតចាប់ផ្តើមផ្ទុះឡើងជាថ្មីដោយគ្រាន់តែវាប្តូរពីអាម៉េរិក និងសូវៀត មកជាអាម៉េរិក និងចិននាពេលបច្ចុប្បន្ន។ ត្រង់ចំណុចនេះក៏ចង់បញ្ជាក់ដែរថា ចិនខុសពីសហភាពសូវៀតកាលពីមុន ចិនបច្ចុប្បន្នគិតសេដ្ឋកិច្ច ដូច្នេះមិនដើរតាមគន្លងចាស់របស់សហភាពសូវៀតទេ។ **ទី៣.**ស្ថានភាពដែលបារាំខឹងអាម៉េរិកនិងអូស្ត្រាលីនៅពេលនេះ បើក្រឡេកមើលកាលពីឆ្នាំ១៩៦៦នៅទីក្រុងភ្នំពេញ សុន្ទរកថារបស់លោកឧត្តមសេនីយ៍ ឆាល ដឺហ្គោល (Charles de Gaulle) បានថ្លែងចំពោះសង្គ្រាមវៀតណាមនាពេលនោះ គឺលោកបានចោទសហរដ្ឋអាម៉េរិកថាមានគំនិត "ឧមត្តភាពនិយម"។ លោកឧត្តមសេនីយ៍ ឆាល ដឺហ្គោល ក៏បានប្រកាសថា *"គេត្រូវឱ្យប្រជាជននីមួយៗសម្រេចនូវជោគវាសនារបស់ពួកគេដោយខ្លួនឯង"*។ សកម្មភាពរបស់អាម៉េរិក បានក្លាយជាប្រវត្តិសាស្ត្រច្រំដែល។ ចំពោះសកម្មភាពរបស់អាម៉េរិកនាពេលនេះ គឺគេចមិនផុតពីគេថាសហរដ្ឋអាម៉េរិកគិតតែខ្លួនឯង តែមិនបានគិតពីសម្ព័ន្ធមិត្ត ដោយកាន់តែជាក់ស្តែងទៀតនោះគេបានប្រៀបធៀបពីការបោះបង់សម្ព័ន្ធមិត្តពីអតីតកាល ដូចជា វៀតណាម កម្ពុជា តៃវ៉ាន់ អាហ្វហ្គានីស្ថាន បារាំង ប៉ុន្តែដោយសារបារាំងជាផ្នែកដ៏សំខាន់របស់អឺរ៉ុបដែលអាម៉េរិកនៅតែអាចទាញប្រយោជន៍បានទៀត ដូច្នេះអាម៉េរិកព្យាយាមចរចារ

ជាមួយបារាំងម្តងហើយម្តងទៀត ដើម្បីបន្សាបកំហឹងរបស់បារាំង។ មេរៀនទាំងនេះយើងមិនអាចឱបឬពឹងមហាអំណាច ដោយមិនបានគិតផលប្រយោជន៍ជាតិនោះទេ។ បច្ចុប្បន្ននឹងអនាគត «*មិនមែនពឹងបរទេសដើម្បីដាក់ទណ្ឌកម្មជាតិខ្លួននោះទេ តែពឹងបរទេសឱ្យមកធ្វើការវិនិយោគ និងបណ្តុះបណ្តាលលើធនធានមនុស្ស*»។

ជុំវិញបញ្ហាលើការកើតឡើងរបស់សម្ព័ន្ធភាពត្រីភាគី AUKUS ទី១.ការបែកបាក់សម្ព័ន្ធមិត្ត ជាក់ស្តែងបារាំងបានកោះហៅឯកអគ្គរដ្ឋទូតរបស់ខ្លួននៅអូស្ត្រាលី និងអាម៉េរិកឱ្យចូលស្រុកវិញនៅថ្ងៃទី១៨ កញ្ញា ឆ្នាំ២០២១។ ប្រមុខការទូតបារាំងលោក ហ្សង់អ៊ីវ ឡឺឌ្រីយ៉ង់ (Jean-Yves Le Drian) បានប្រើពាក្យធ្ងន់ៗលើអូស្ត្រាលី និងអាម៉េរិក ពិសេសគឺអាម៉េរិក។ *“ចិត្តវៀចវេរ” “ការមើលងាយ” “ ការនិយាយភូតភរ” “យើងជាសម្ព័ន្ធមិត្តនឹងគ្នា ហើយនៅពេលដែលគេមានសម្ព័ន្ធមិត្តម្នាក់ គេមិនដែលធ្វើអំពើជាមួយសម្ព័ន្ធមិត្តតាមបែបឃោរឃៅ និងដោយមិនអាចទាយទុកមុនបានរបៀបនេះទេ” ។* ទី២.កិច្ចព្រមព្រៀងសម្ព័ន្ធមិត្ត តែនៅអាចបោះបង់សម្ព័ន្ធមិត្ត។ តួយ៉ាងសង្គ្រាមនៅអាហ្វហ្គានីស្ថានត្រូវបានចាប់ផ្តើមឡើង នៅខែតុលា ឆ្នាំ២០០១ ប្រមាណ១ខែក្រោយភេរវកម្ម ថ្ងៃទី១១កញ្ញា នៅញូវយ៉ក រហូតដល់ខែឧសភាឆ្នាំ២០១២ លោកអូបាម៉ាបានទៅអាហ្វហ្គានីស្ថានដើម្បីចុះកិច្ចព្រមព្រៀងជាដៃគូយុទ្ធសាស្រ្តអាម៉េរិក-អាហ្វហ្គានីស្ថាន។ ចំពោះកិច្ចព្រមព្រៀងនាពេលនោះ ក៏មានចែងថា អាហ្វហ្គានីស្ថានត្រូវបានចាត់បញ្ចូលជាប្រទេសសម្ព័ន្ធមិត្តចម្បងរបស់អាម៉េរិក ដូចជាប្រទេសសម្ព័ន្ធមិត្តចម្បងៗផ្សេងទៀតដែរ រួមមាន អ៊ីស្រាអែល អេហ្ស៊ីប អូស្ត្រាលី ជប៉ុន កូរ៉េខាងត្បូង ថៃ ហ្វីលីពីន ជាដើម។ តែនៅពេលបច្ចុប្បន្នអាម៉េរិករត់ចេញពីសម្ព័ន្ធមិត្តអាហ្វហ្គានីស្ថាន។ ទី៣.បក្សសម្ព័ន្ធថ្មីនេះធ្វើឱ្យអឺរ៉ុបដាក់ការសង្ស័យតើគួរជ្រើសរើសចិនឬអាម៉េរិក? អឺរ៉ុបបានចាប់ផ្តើមជជែកថាតើ រវាងអាម៉េរិក និងចិន គួររើសយកខាងណា? អឺរ៉ុបក៏កំពុងពិចារណាផងដែរ អំពីការបង្កើតកម្លាំងទ័ពពិសេសមួយ សម្រាប់ខ្លួនឯង ដែលមានកម្លាំងទាហាន ៥០០០នាក់ ចេញប្រតិបត្តិការរក្សាសន្តិភាព។ ទី៤.បញ្ហាកូរ៉េខាងជើងចំពោះសហរដ្ឋអាម៉េរិក តែលើកឡើងជាបញ្ហា “ការរត់ប្រណាំងអាវុធនុយក្លេអ៊ែរ” ប៉ុន្តែសហរដ្ឋអាម៉េរិក អង់គ្លេស យល់ព្រមផ្ទេរបច្ចេកវិទ្យាផលិតនាវាមុជទឹកដើរដោយថាមពលនុយក្លេអ៊ែរឱ្យទៅអូស្ត្រាលី។ ទី៥.សម្ព័ន្ធមិត្តថ្មីត្រីភាគីនេះ បានធ្វើឱ្យអាស៊ានឈឺក្បាលបារម្ភផងដែរ ព្រោះនៅក្នុងសន្ធិសញ្ញាក្រុងបាងកកឆ្នាំ១៩៩៥ អាស៊ានបានប្តេជ្ញាធ្វើឱ្យអាស៊ីអាគ្នេយ៍ជាតំបន់គ្មានអាវុធនុយក្លេអ៊ែរ។ ទី៦. ការដាក់ទណ្ឌកម្មទៅវិញទៅមក អ្នកដែលទទួលរងនូវផលប៉ះពាល់គឺប្រជាជន តួយ៉ាង អង់គ្លេសចូលរួមជាសម្ព័ន្ធភាពត្រីភាគី AUKUS និងជាពិសេសអង់គ្លេស បានប្រើប្រាស់នាវាឆ្លងកាត់ សមុទ្រចិនខាងត្បូង និងបានធ្វើសមយុទ្ធជាមួយសម្ព័ន្ធមិត្តនៅក្បែរតៃវ៉ាន់។ ជាហេតុដែលនាំឱ្យចិនបានបង្ខំចិត្តហាមឃាត់ការនាំចូលសាច់គោអង់គ្លេសជាថ្មីម្តងទៀតដោយសំអាងហេតុផលថា មានជំងឺលើសត្វគោ។

បើតាមច្បាប់អន្តរជាតិវិញចំពោះសម្ព័ន្ធត្រីភាគី AUKUS និង Quad មានភាពស្រដៀងគ្នាច្រើន។ ចំពោះកិច្ចសន្ទនាសន្តិសុខចតុភាគី(Quad) និងបក្សសម្ព័ន្ធត្រីភាគី AUKUS មានសកម្មភាពនិងគោលដៅដូចគ្នាត្រង់ជាសម្ព័ន្ធមិត្តយុទ្ធសាស្ត្រ គ្មានរចនាសម្ព័ន្ធ គ្មានសន្ធិសញ្ញារួម គ្មានកតិកាសញ្ញាការពារផ្លូវការ និងគ្មានទីបញ្ជាការដ្ឋាន ដូចជាអង្គការអូតង់ទេ ជាក់ស្តែងអង្គការណាតូ (NATO) នៅមាត្រា៥ បានចែង*ថា “ការវាយប្រហារប្រដាប់អាវុធប្រឆាំងនឹងប្រទេសមួយ ឬ ច្រើនជាងក្នុងចំណោមប្រទេសទាំងអស់នៅអឺរ៉ុប ឬ នៅអាម៉េរិកខាងជើង នឹងត្រូវបានគេចាត់ទុកថាជាការវាយប្រហារមួយប្រឆាំងប្រទេសទាំងអស់នោះ” ។* ត្រង់ចំណុចនេះ ទី១.បើមានបញ្ហាកើតឡើងមែន «ថ្វីបើសម្ព័ន្ធត្រីភាគី AUKUS មិនដូចអង្គការណាតូនៅមាត្រា៥ តែក្នុងចំណោមសមាជិកសម្ព័ន្ធត្រីភាគី នៅតែជាសមាជិករបស់ណាតូ»។ ដូច្នេះហេតុផលទាំងនេះ ទើបចិនបារម្ភខ្លាំងនៃសង្គ្រាមត្រជាក់ថ្មី និងការរត់ប្រណាំងអាវុធនុយក្លេអ៊ែរ ដែលប៉ះពាល់ដោយផ្ទាល់និងប្រយោលដល់សន្តិសុខប្រទេសចិ

ន។ ទី២.ប្រទេសជាសម្ព័ន្ធនឹងរងឥទ្ធិពលនៃការប្រកួតប្រជែងរបស់មហាអំណាច។ ទី៣.ជាការបន្តពង្រឹងអំណាចយោធាដែនទឹករបស់អាម៉េរិក ទី៤.ការអូសទាញសម្ព័ន្ធមិត្ត និងបង្កើតសម្ព័ន្ធភាពដើម្បីទប់ទល់ឥទ្ធិពលរបស់ចិន។

ដូច្នេះតើមហាអំណាចប្រើវិធីដើម្បីដំណោះស្រាយបែបណា? ដើម្បីដំណោះស្រាយខាងលើឃើញថាចិននិងអាម៉េរិកបានអនុវត្តន៍នាពេលកន្លងមកឃើញថា ទី១.ក្នុងអតីតកាល ពេលចិនមានបញ្ហាជាមួយសហរដ្ឋអាម៉េរិក ចិនទៅរកសហភាពសូវៀត ពេលបច្ចុប្បន្នចិនមានបញ្ហាជាមួយអាម៉េរិកទៀត ចិននៅតែរករុស្ស៊ី ចំណែកឯរុស្ស៊ីក៏ដូចគ្នា ពេលមានបញ្ហាជាមួយអឺរ៉ុប និងអាម៉េរិកក៏ខិតទៅរកចិនដែរ។ ទី២.ការដាក់ទណ្ឌកម្មដោយផ្ទាល់ទៅវិញទៅមក និងការដាក់ទណ្ឌកម្មលើសម្ព័ន្ធមិត្ត ទី៣.ការចរចារការទូត និងការចរចារដោយប្រយោល និងផ្ទាល់រវាងថ្នាក់ដឹកនាំទាំងពីរ។ ជុំវិញដំណោះស្រាយបច្ចុប្បន្នអាចយល់បានថា ទី១.ចំពោះអូស្ត្រាលីបើយល់ថានាវាអាម៉េរិកល្អ គួរទិញទាំងពីរ ឬផ្លាស់ប្តូរនៃការទិញ។ ម្យ៉ាងទៀត ពេលផុតកិច្ចសន្យាជាមួយបារាំង អាចឈប់ទិញបាន ជាជាងធ្វើឱ្យបរាជ័យជាមួយសម្ព័ន្ធភាព ទាំងមិនទាន់តតាំងជាមួយចិនផង។ ទី២.សម្ព័ន្ធមិត្តអាម៉េរិកដើម្បីសេដ្ឋកិច្ចនិងសន្តិសុខជាតិរបស់ខ្លួន ក៏គួររៀនតាមអាម៉េរិកដែរ ពោលគឺអាម៉េរិកបានជំរុញឱ្យមានការរកស៊ីជាមួយចិនបន្ថែមទៀត ទោះជាមានទំនាក់ទំនងល្អក់កករជាមួយចិនក៏ដោយ ស្របពេលដែលសកម្មភាពជាក់ស្តែង សហរដ្ឋអាម៉េរិកជំរុញឱ្យសម្ព័ន្ធមិត្តប្រជែងនិងបន្សាបឥទ្ធិពលចិន។ ទី៣.ចិនចង់ឈ្នះលើសម្ព័ន្ធមិត្តត្រីភាគីនេះ លុះត្រាតែសម្ព័ន្ធរបស់ចិនរឹងមាំ សេដ្ឋកិច្ចខ្លាំងពិតប្រាកដ។ ចិនមិនត្រូវឱ្យប្រទេសសម្ព័ន្ធមិត្តក្លាយជាស្រីលង្កាទី២ទេ។ ពេលដែលសម្ព័ន្ធមិត្តចិនខ្លាំងនឹងធ្វើឱ្យនយោបាយការបរទេសរបស់សម្ព័ន្ធភាពចិនខ្លាំងសមិទ្ធិផលនោះក៏នឹងធ្វើឱ្យនយោបាយការបរទេសចិនរឹងមាំ។ ទី៤.អាម៉េរិកមិនគួរយកតំបន់ឥណ្ឌូប៉ាស៊ីហ្វិកដើរតាមគម្រូមជ្ឈឹមបូព៌ាទេ។ ទី៥.មហាអំណាចទាំងពីរត្រូវគិតដល់សន្តិសុខពិភពលោក។

ជារួមកិច្ចសន្ទនាសន្តិសុខចតុភាគី Quad និងសម្ព័ន្ធភាពត្រីភាគី AUKUS ជាការចិញ្ចឹមរៃបន្ថែមឱ្យស្រែកដាក់ចិនមិនឱ្យដេកលក់ ហើយក៏ជាសម្រែកការទូតដែលបន្ថែមបញ្ហាដល់ចិន។ ចំណុចនៃការកើតឡើងនៃបក្សសម្ព័ន្ធថ្មីរបស់អាម៉េរិក ទី១.បានដណ្តើមទីផ្សាររបស់បារាំងដែលអាម៉េរិកអាចលក់នាវានុយក្លេអ៊ែរ និងអាចតភ្ជាប់លក់បរិក្ខាយោធាផ្សេងទៀត។ ទី២.ការកកើតបក្សសម្ព័ន្ធមិត្តថ្មីជាការបង្កើតបន្ថែមផ្លូវបន្ទាប់ពីQuad។ ទី៣.ជាការប្រជែងជាមួយចិននិងបន្ថែមឧបសគ្គដល់ចិន។ ទី៤.កិច្ចព្រមព្រៀងនេះគឺជាដៃគូការពារជាតិដ៏ធំបំផុតក្នុងចំណោមកិច្ចព្រមព្រៀងផ្សេងទៀត ហើយអនាគតនឹងមានសមាជិកផ្សេងទៀតចូលរួម។ ទី៥. ចិននិងរុស្ស៊ីមានការខិតជិតគ្នាបន្ថែម ហើយនៅក្នុងតំបន់នឹងបន្តមានការប្រកួតប្រជែងឥទ្ធពលគ្នា។ ទី៦.ការសម្រេចចិត្តជាឯកតោភាគីដែលអាម៉េរិកដើរផ្ទុយពីពហុភាគីនិយម និងធ្វើឱ្យសម្ព័ន្ធអាម៉េរិកលែងទុកចិត្តដូចមុន។ ទី៧.ការភ្ជាប់ខ្លួនមកតំបន់ឥណ្ឌូប៉ាស៊ីហ្វិករបស់អាម៉េរិកនិងសម្ព័ន្ធមិត្តក្នុងហេតុផល *លើកកម្ពស់សន្តិសុខ វិបុលភាព សេរីភាពនាវាចរ* ដូចជា បញ្ហាតៃវ៉ាន់ សមុទ្រចិនខាងត្បូង ជាដើមនោះនឹងធ្វើឱ្យកិច្ចសន្ទនាសន្តិសុខចតុភាគី(Quad)សម្ព័ន្ធមិត្តត្រីភាគី AUKUS មានចលនាសកម្ម រួមទាំងការលើកឡើងជាប្រធានបទបន្តយកមកជជែកវែកញែក៕